ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

Media from www.moj.gov.kh

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានកំណត់ឱ្យមានប្រាក់បំណាច់មុខងារប្រចាំខែសម្រាប់មន្ត្រីរាជការ ក្រសួងមហាផ្ទៃ ដែលមានមុខតំណែងជានាយករដ្ឋបាល ក្នុងរចនាសម្ព័ន្ធសាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក និងសាលាខណ្ឌ ។

មាត្រា ២.-

ប្រាក់បំណាច់មុខងារប្រចាំខែរបស់នាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់រៀបចំដូចខាងក្រោម :

ល.រ	មុខងារ	កម្រិត ៥	កម្រិត៤	កម្រិត ៣	កម្រិត ២	កម្រិត ១
១-	នាយករដ្ឋបាលរាជធានី ខេត្ត	៦១៥ ០០០ ៛	៦៣៥ ០០០ ៛	៦៩៣ ០០០ ៛	៧៣៦ ០០០ ៛	៧៨១ ០០០ ៛
២-	នាយករដ្ឋបាលក្រុង ស្រុក ខណ្ឌ	៧១ ០០០ ៛	៨១ ៧០០ ៛	៩៤ ០០០ ៛	១០៨ ១០០ ៛	១២៤ ៣០០ ៛

មាត្រា ៣.-

រយៈពេល និងបទពិសោធន៍ការងារសម្រាប់កម្រិតនីមួយៗ ការផ្លាស់ប្តូរ និង ការផ្តល់ប្រាក់បំណាច់មុខងារសម្រាប់មុខតំណែងនាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមមាត្រា១៤ និង មាត្រា១៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៤.-

ការកែប្រែប្រាក់បំណាច់មុខងារនាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងដោយ អនុក្រឹត្យ ។

ROYAUME DU CAMBODGE
Media from www.moj.gov.kh

16/05/2021

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៩៧.០៩០៥.៤៩២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០០៩

លេខ : ៤៤៧.ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៩

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ជិនកេន

Media from www.moj.gov.kh